Declassified to Public
06 September 2012

អ-ហ/ស-A36

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ជូនលោកចៅក្រម យូ ប៊ុនឡេង

ជូនលោកចៅក្រម **Marcel Lemonde**

ការិយាល័យសហចៅក្រមស៊ើបអង្កេត

អង្គជំនុំជម្រះវិសាមញ្ញ

ភ្នំពេញ ថ្ងៃទី ៣ ខែ~~កញ្ញា~~ តុលា ២០០៧

**កម្មវត្ថុ: ការចាត់តាំងសហមេធាវីសម្រាប់លោកកាំង ហ្កេកអ៊ាវ**

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៧ ខ្ញុំបានចាត់តាំងលោកមេធាវីការ សាវុត្ថ និងលោកមេធាវី François ROUX ដើម្បីការពាររឿងក្តីរបស់លោកកាំង ហ្កេកអ៊ាវ រងចាំការសម្រេចអំពីមធ្យោបាយហិរញ្ញវត្ថុរបស់គាត់ ។ សហចៅក្រមសស៊ើបអង្កេតទទួលស្គាល់ការចាត់តាំងនេះមកត្រឹមបំណាច់ខែសីហា ។

នៅថ្ងៃទី ២៣ ខែសីហា ២០០៧ ខ្ញុំសម្រេចថាលោកកាំង ហ្កេកអ៊ាវជាជនក្រីក្រ ហើយ អង្គការសហប្រជាជាតិត្រូវបង់ប្រាក់កម្រៃសេវាមេធាវីរបស់គាត់ ។

ប៉ុន្តែទម្រង់នៃកិច្ចសន្យាសម្រាប់សហមេធាវីដែលជាមូលដ្ឋានគ្រឹះនៃគ្រោងការជំនួយការច្បាប់ មិនទាន់បានអនុម័តដោយការិយាល័យកិច្ចការច្បាប់ និង គ្រប់គ្រងធនធានមនុស្សនៃអង្គការសហប្រជាជាតិនៅឡើយទេ ពួកគេទទួលកិច្ចសន្យានេះនៅថ្ងៃទី ១២ ខែសីហា ហើយរូបខ្ញុំផ្ទាល់ជួបពួកគេនៅទីក្រុងញូយ៉កកាលពីថ្ងៃទី ៦ ខែសីហា ដើម្បីបញ្ចុះបញ្ចូលពួកគេឲចាត់សកម្មភាពឆាប់រហ័ស ។ ប៉ុន្តែពួកគេស្នើសុំពេលមួយខែទៀតដើម្បីពិចារណា ។

នៅក្នុងកាលៈទេសៈបែបនេះ វាហាក់ដូចជាឥតអៀនខ្មាស់ពេកក្នុងការចាត់តាំងសហមេធាវីឲការពាររឿងក្តីជាអចិន្ត្រៃ ក្នុងខណៈដែលទម្រង់កិច្ចសន្យាចុងក្រោយដែលពួកគេនឹងចុះហត្ថលេខា មិនទាន់អនុម័តនៅឡើយ ហេតុដូច្នេះខ្ញុំត្រូវតែបន្តចាត់តាំងសហមេធាវីជាបណ្តោះអាសន្នរហូតដល់បំណាច់ខែ~~កញ្ញា~~ តុលា ។ ខ្ញុំស្នើសុំសហចៅក្រមចៅស៊ើបអង្កេតទទួលស្គាល់ការចាត់តាំងបណ្តោះអាសន្ននេះ ។

ខ្ញុំនឹងជំរុញអ្នកដែលទទួលខុសត្រូវនៅអង្គការសហប្រជាជាតិបំពេញកិច្ចការរបស់ពួកគេនៅក្នុងរយៈពេលមួយខែដែលពួកគេស្នើសុំ ។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

ខ្ញុំអាចបញ្ជាក់ជូនលោកថាលោកស្រី Heleyn UNAC និង លោក ចាន់ រ៉ាវុធ ត្រូវបានតែងតាំងជាទីប្រឹក្សាពិគ្រោះយោបល់ផ្នែកច្បាប់ និង អ្នកគ្រប់គ្រងសំណុំរឿងនៅក្នុងរឿងក្ដីនេះ ដោយអង្គភាពគាំពារការការពារក្ដី ។

ដោយក្ដីរាប់អាន

Rupert Skilbeck

ចំលងជូន: លោកកាំង ហ្គេកអ៊ាវ

លោកមេធាវី ការ សាវុត្ថ

លោកមេធាវី François ROUX